ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨.១៣-០២៤ ... ប.១.៧ ... ធ.ជ.ក

# វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០២៣ និងទស្សនវិស័យឆ្នាំ២០២៤

រៀបចំដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

ឈឈឈ✵សសស

សេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៣ ត្រូវបានមូលនិធិរូបិយវត្ថុអន្តរជាតិព្យាករថាមានកំណើន ៣% ទាបជាងឆ្នាំមុន (៣,៥%) ដោយសារការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ដែលបានដាក់សម្ពាធលើការប្រើប្រាស់និងវិនិយោគ ស្របពេលដែលភាពតានតឹងភូមិសាស្ត្រនយោបាយ បានជះឥទ្ធិពលអវិជ្ជមានដល់កំណើនផលិតកម្ម និងពាណិជ្ជកម្មអន្តរជាតិ។

នៅកម្ពុជា កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថាបន្តងើបឡើងក្នុងអត្រា ៥,៥% ខ្ពស់ជាងឆ្នាំមុនបន្តិច (៥,២%) ដែលគាំទ្រជាចម្បងដោយកំណើនវិស័យទេសចរណ៍និងផលិតផលកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីជាវិស័យកាត់ដេរ សំណង់ អចលនទ្រព្យ និងកសិកម្មមានកំណើនទាបក៏ដោយ។ វិស័យទេសចរណ៍បានកើនឡើងជាលំដាប់ និងបានរួមចំណែកជំរុញការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកដែលពាក់ព័ន្ធ ដូចជា ការដឹកជញ្ជូន ពាណិជ្ជកម្ម និងទូរគមនាគមន៍ ជាដើម។ ការនាំចេញផលិតផលមិនមែនកាត់ដេរ ដូចជា គ្រឿងអេឡិចត្រូនិក គ្រឿងបន្លាស់រថយន្ត និងបន្ទះសូឡាទទួលបានកំណើនល្អ ខណៈដែលការនាំចេញសម្លៀកបំពាក់និងស្បែកជើង បានទទួលរងផលប៉ះពាល់ពីការធ្លាក់ចុះតម្រូវការនៃប្រទេសដៃគូពាណិជ្ជកម្មចម្បងៗ ជាពិសេស សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ វិស័យសំណង់ ទទួលបានកំណើនទាប ដែលជាចម្បងត្រូវបានជំរុញដោយការវិនិយោគ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ខណៈដែលការវិនិយោគបរទេសនៅក្នុងវិស័យអចលនទ្រព្យបានថយចុះ។ វិស័យកសិកម្មបានកើនឡើងបន្តិច ដែលគាំទ្រដោយកំណើនតម្រូវការក្រៅប្រទេស និងភាពអំណោយផលនៃកត្តាអាកាសធាតុ។

ខណៈដែលអត្រាអតិផរណាពិភពលោកបានថយចុះដល់ ៦,៩% អត្រាអតិផរណាកម្ពុជាបានថមថយមកកម្រិតជាមធ្យម ២,១% នាឆ្នាំ២០២៣ ពី ៥,៤% នាឆ្នាំ២០២២ ដោយសារការធ្លាក់ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងការថយល្បឿននៃកំណើនថ្លៃម្ហូបអាហារ។ អតិផរណាក្នុងកម្រិតទាប ក៏បានរួមចំណែកដោយការថយចុះអតិផរណានាំចូល ដែលជាលទ្ធផលទទួលបានពីការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។ អត្រាប្តូរប្រាក់ជាមធ្យមមានកម្រិត ៤.១១០ រៀលក្នុងមួយដុល្លារអាមេរិក ហើយនៅចុងខែធ្នូ ឆ្នាំ២០២៣ អត្រាប្តូរប្រាក់បានថយចុះបន្តិចមក ៤.០៨១ រៀលក្នុងមួយដុល្លារអាមេរិក ដែលមានន័យថា តម្លៃប្រាក់រៀលឡើងថ្លៃ ០,៨៧% ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២២។ ស្ថិរភាពប្រាក់រៀលបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃ អំណាចទិញរបស់ប្រាក់រៀលក៏ដូចជាចំណូលអ្នកប្រើប្រាស់ និងរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ច


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជារូម។ លទ្ធផលនេះសម្រេចបានតាមរយៈការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន ដោយធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ទិញប្រាក់រៀលនៅលើទីផ្សារប្តូរប្រាក់ ៥៧៣ ប៊ីលានរៀល (១៣៩,១លានដុល្លារអាមេរិក) និងប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗ ដើម្បីស្រូបយកប្រាក់រៀលលើសប្រមាណ ១៥,២ ទ្រីលានរៀល (៣,៧ ប៊ីលានដុល្លារអាមេរិក) ពីក្នុងសេដ្ឋកិច្ច និងរក្សាការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតសមស្រប។ ទោះយ៉ាងណា ដុល្លាររូបនីយកម្មដែលមានកម្រិតខ្ពស់ (ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅមានកម្រិត ៨៣,៤%) នៅតែជាឧបសគ្គដល់ការអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព ជាពិសេសការជះឥទ្ធិពលលើអត្រាការប្រាក់ទីផ្សារ ដើម្បីជួយជំរុញការប្រើប្រាស់និងវិនិយោគក្នុងស្រុកសម្រាប់គាំទ្រកំណើនឱ្យកាន់តែសកម្ម។

ចំពោះវិស័យខាងក្រៅ ជញ្ជីងទូទាត់កម្ពុជាបន្តមានអតិរេក ០,៧% នៃផ.ស.ស ធៀបនឹងឆ្នាំមុន ១,២% នៃផ.ស.ស ដោយសារតែទទួលបានការគាំទ្រពីកំណើនវិនិយោគផ្ទាល់បរទេស ១៤,៥% និងនៅពេលដែលឱនភាពជញ្ជីងពាណិជ្ជកម្មបានធ្លាក់មកត្រឹម ៨,៦% នៃផ.ស.ស ដោយសារការនាំចូលថយចុះ ខណៈដែលការនាំចេញបានកើនឡើងបន្តិច។ អតិរេកនេះបានរួមចំណែកគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើង ១២,៣% ដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលជាកម្រិតខ្ពស់គ្រប់គ្រាន់ស្មើនឹងជាង ៧ខែនៃការនាំចូលទំនិញនិងសេវានៅគ្រាបន្ទាប់ ធៀបនឹង ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

ទន្ទឹមនឹងការងើបឡើងនៃសេដ្ឋកិច្ច ប្រព័ន្ធធនាគារដែលបន្តគ្របដណ្តប់វិស័យហិរញ្ញវត្ថុ ក៏បានដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រដល់វិស័យសេដ្ឋកិច្ចចម្បងៗផងដែរ បើទោះបីល្បឿនកំណើនឥណទានបានថមថយក៏ដោយ។ កំណើនឥណទានបានថមថយមកត្រឹម ៤,៨% ដែលជាអត្រាទាបបំផុតក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយ ដោយសារការងើបឡើងយឺតនៃវិស័យមួយចំនួន។ ឥណទានគ្រឹះស្ថានធនាគារទៅកាន់វិស័យសណ្ឋាគារនិងភោជនីយដ្ឋានកើនឡើង ០,៦% ខណៈដែលការជួញដូរដុំកើន ៤,៨% ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួនកើន ៦,៤% ការជួញដូរអចលនទ្រព្យកើន ១៦,៩% និងសំណង់កើន ១៣,៩%។ ក្នុងស្ថានភាពនេះ បទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនត្រូវបានអនុគ្រោះ ដើម្បីផ្តល់លទ្ធភាពបន្ថែមដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការជួយទ្រទ្រង់វិស័យដែលត្រូវការហិរញ្ញប្បទានដើម្បីរក្សានិរន្តរភាព និងពង្រីកការវិនិយោគ។ ការពន្យារពេលអនុវត្តការបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកនិងបទប្បញ្ញត្តិផ្សេងៗ បានផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសន្ទនីយភាពបន្ថែមប្រមាណ ១,២ ប៊ីលានដុល្លារអាមេរិក ដើម្បីផ្តល់ឥណទានទៅវិស័យអាទិភាព។ ក្រៅពីនេះ ប្រព័ន្ធធនាគារបាននិងកំពុងរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុស្ត្រី និងការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាព ដើម្បីពង្រឹងការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ក្រោមឥទ្ធិពលនៃការដំឡើងអត្រាការប្រាក់ខ្ពស់លើទីផ្សារអន្តរជាតិ អត្រាការប្រាក់នៅកម្ពុជាបានកើនឡើងកាលពីឆ្នាំ២០២២ តែបានចុះមកវិញបន្តិចនៅឆ្នាំ២០២៣ ដោយអត្រាការប្រាក់ឥណទានវិស័យធនាគារជារៀលនិងជាដុល្លារអាមេរិកបានថយចុះបន្តិចមកដល់ ១៣,៣៩% និង ១១,០៨% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ (១៣,៥១% និង ១១,២៩%) ខណៈពេលដែលអត្រាការប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិកបានកើនបន្តិចដល់ ៧,៧% និង ៦,៤៧% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ ដែលមានកម្រិត ៦,៨៨% និង ៥,៣៦%។ ទោះយ៉ាងណា វិស័យមីក្រូហិរញ្ញវត្ថុបន្តទទួលរងឥទ្ធិពលពីកំណើន

អត្រាការប្រាក់អន្តរជាតិ ដោយសារប្រភពមូលនិធិភាគច្រើនទទួលបានពីកម្ចីខាងក្រៅ។ អត្រាការប្រាក់ឥណទានជាមធ្យមក្នុងវិស័យមីក្រូហិរញ្ញវត្ថុជារៀល និងជាដុល្លារអាមេរិកបានកើនឡើងបន្តិចដល់ ១៧,៨៥% និង ១៦,២% រៀងគ្នា ពី ១៦,៨% និង ១៥,១% នៅឆ្នាំ២០២២ ស្របពេលដែលអត្រាការប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិកបានកើនបន្តិចដល់ ៨,៣៩% និង ៨,២៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ ដែលមានកម្រិត ៧,៤២% និង៧,៣៨%។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្ម និងបានរួមចំណែកគាំទ្រដល់ឌីជីថលូបនីយកម្មសេដ្ឋកិច្ច-សង្គមកម្ពុជា តាមរយៈការលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាព និងសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍។ លើសពីនេះ ភាពងាយស្រួលក្នុងការទទួលបានសេវាទូទាត់ក៏បានលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់រៀលផងដែរ។ ជាក់ស្តែង ទំហំទឹកប្រាក់ទូទាត់ជាអេឡិចត្រូនិកសរុបបានកើនឡើង ៧៨% ស្មើនឹងជាង ៧ដងនៃផ.ស.ស ដែលក្នុងនោះការទូទាត់តាមប្រព័ន្ធបាគងជារៀលបានកើនឡើង ៣,៥ដង និងជាដុល្លារអាមេរិកកើនឡើង ២,៥ដង។ ប្រព័ន្ធទូទាត់ត្រូវបានតភ្ជាប់ជាមួយប្រទេសនិងបណ្តាញទូទាត់អន្តរជាតិដូចជា ថៃ ម៉ាឡេស៊ី ឡាវ វៀតណាម និងក្រុមហ៊ុនផ្តល់សេវាទូទាត់អន្តរជាតិមួយចំនួន ហើយបាន និងកំពុងតភ្ជាប់ជាមួយប្រទេសចិន ឥណ្ឌា ជប៉ុន សិង្ហបុរី និងប្រទេសផ្សេងទៀតក្នុងតំបន់។

ក្នុងពេលដែលភាពមិនប្រាកដប្រជានៅមានកម្រិតខ្ពស់នៅឡើយ ដោយសារហានិភ័យនៃការបន្តអូសបន្លាយវិបត្តិភូមិសាស្ត្រនយោបាយ និងកំណើនយឺតនៅប្រទេសដែលមានសេដ្ឋកិច្ចធំៗមួយចំនួន នៅឆ្នាំ២០២៤ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងបន្តថមថយបន្តិចថែមទៀតធៀបនឹងឆ្នាំ២០២៣។ នៅកម្ពុជា សេដ្ឋកិច្ចត្រូវបានរំពឹងដោយសុទិដ្ឋិនិយមថានឹងបន្តងើបឡើងបន្ថែមទៀតក្នុងរង្វង់ ៦,៥% ដែលគាំទ្រជាចម្បងដោយការកើនឡើងនៃវិស័យទេសចរណ៍ និងវិស័យកម្មន្តសាល។ វិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងងើបឡើង ដោយសារភាពប្រសើរឡើងនៃស្ថានភាពទេសចរណ៍ក្នុងតំបន់ ព្រមទាំងការបន្តអភិវឌ្ឍនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលនឹងគាំទ្រដល់វិស័យនេះ។ តាមរយៈការអនុវត្តច្បាប់វិនិយោគថ្មី វិស័យកម្មន្តសាលត្រូវបានរំពឹងថានឹងសម្រេចបានកំណើនល្អជាងឆ្នាំ២០២៣ ជាពិសេស ផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ហើយវិស័យកាត់ដេររំពឹងថានឹងងើបឡើងជាលំដាប់។ វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ជាងឆ្នាំ២០២៣បន្តិច ដោយទទួលបានអត្ថប្រយោជន៍ពីការបន្តធ្វើពិពិធកម្មទីផ្សារទៅកាន់ប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនានា គួបផ្សំនឹងគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយផលិតកម្ម និងទីផ្សារ។ វិស័យសំណង់និងអចលនទ្រព្យដែលបានទទួលរងឥទ្ធិពលពីវិបត្តិកន្លងមកត្រូវបានព្យាករថានឹងបន្តមានកំណើនទាប ដែលនឹងបន្តទទួលបានការគាំទ្រពីគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គួបផ្សំនឹងការងើបឡើងវិញសន្សឹមៗនៃតម្រូវការក្នុងស្រុក ដែលផ្តោតលើលំនៅឋានដែលមានតម្លៃសមរម្យ ក្នុងពេលដែលតម្រូវការសំណង់ប្រណីតដែលបម្រើដល់អនិវាសនជន ត្រូវបានរំពឹងថានឹងបន្តមានភាពទន់ខ្សោយ។ អតិផរណានៅឆ្នាំ២០២៤ ត្រូវបានព្យាករថាមានកម្រិត ២,៥% ខ្ពស់ជាងឆ្នាំ២០២៣បន្តិច ដែលជាចម្បងដោយសារការរំពឹងថាថ្លៃប្រេង

ឆៅពិភពលោកអាចនឹងកើនឡើង បន្ទាប់ពីក្រុមប្រទេសនាំចេញប្រេងមានគម្រោងកាត់បន្ថយការផ្គត់ផ្គង់។

ក្នុងបរិការណ៍នេះ ការបន្តអនុវត្តនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន នឹងបន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀល ព្រមទាំងបន្តរួមចំណែករក្សាស្ថិរភាពថ្លៃនិងការពារអំណាចទិញនៃប្រាក់រៀល។ ក្របខណ្ឌនយោបាយរូបិយវត្ថុនឹងត្រូវពង្រឹង ជាពិសេស ការអភិវឌ្ឍឧបករណ៍និងទីផ្សាររូបិយវត្ថុស្របពេលគ្នានឹងការដាក់ចេញឱ្យប្រើប្រាស់សាកល្បងអត្រាការប្រាក់គោលរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីតម្រង់ទិសអត្រាការប្រាក់ជារៀលនៅលើទីផ្សារឱ្យមានកម្រិតសមស្រប។ សំខាន់ដូចគ្នានេះ ការរក្សាស្ថិរភាពហិរញ្ញវត្ថុជាអាទិភាពមួយក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពមិនច្បាស់លាស់ និងមានកំណើនយឺត ដែលទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការតាមដាននិងវាយតម្លៃជាប្រចាំលើហានិភ័យ ដែលអាចកើតឡើងជាយថាហេតុ និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន។ ការពង្រឹងស្ថិរភាពហិរញ្ញវត្ថុក៏ដូចជាប្រសិទ្ធភាពនយោបាយរូបិយវត្ថុ ជាពិសេស ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល នឹងបន្តទាមទារឱ្យមានការរួមចំណែក និងកិច្ចសហការពីភាគីពាក់ព័ន្ធតាមវិស័យនានា និងសាធារណជន។

ទន្ទឹមនឹងការព្យាករដោយសុទិដ្ឋិនិយម សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ក្នុងនោះកត្តាខាងក្រៅរួមមាន៖ i/-កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចប្រទេសជាដៃគូពាណិជ្ជកម្មចម្បងៗរបស់កម្ពុជា ដូចជា ចិន អាមេរិក និងអឺរ៉ុប ដែលអាចប៉ះពាល់ដល់លំហូរវិនិយោគនាំចេញ និងទេសចរណ៍ ii/-ប្រក្រតីកម្មនយោបាយរូបិយវត្ថុនៃប្រទេសអភិវឌ្ឍន៍ធំៗប្រព្រឹត្តទៅយឺតជាងការរំពឹងទុក ដែលអាចដាក់សម្ពាធលើការខ្ចីពីក្រៅប្រទេស និងអត្រាការប្រាក់នៅកម្ពុជា iii/-ការកើនឡើងនៃភាពតានតឹងនិងការបែងចែកភូមិសាស្ត្រនយោបាយពិភពលោក អាចរាំងស្ទះដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងបង្អាក់សន្ទុះកំណើនការនាំចេញនិងវិនិយោគ iv/-កត្តាប្រែប្រួលអាកាសធាតុដែលធ្វើឱ្យវិស័យកសិកម្មមានកំណើនទាប ជាពិសេស បាតុភូតអែលនីញ៉ូ ដែលត្រូវបានព្យាករថានឹងមានឥទ្ធិពលខ្លាំងជាងឆ្នាំ២០២៣ និង v/-លទ្ធភាពកើនឡើងនៃឧក្រិដ្ឋកម្មសាយប័រ អាចប៉ះពាល់ដល់ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធទូទាត់ឌីជីថល និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ទន្ទឹមនេះ ហានិភ័យខាងក្នុង រួមមាន៖ i/- ការកើនឡើងនៃឥណទានមិនដំណើរការ អាចបន្ថយកំណើនឥណទានសម្រាប់ការប្រើប្រាស់និងការវិនិយោគ និង ii/-កំណើននៃវិស័យសំណង់និងអចលនទ្រព្យអាចបន្តមានកម្រិតទាប និងអាចមានឥទ្ធិពលបន្តលើវិស័យផ្សេងទៀត ដូចជាវិស័យធនាគារ ជាដើម។ ជាមួយគ្នានេះ កម្ពុជាក៏នៅប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធចម្បងៗ ដូចជា i/-ពិពិធកម្មសេដ្ឋកិច្ចនិងការនាំចេញនៅមានសន្ទុះយឺត ii/-សមត្ថភាពជំនាញ និងផលិតភាពនៅមានកម្រិត iii/-ថ្លៃដឹកជញ្ជូននិងអគ្គិសនីខ្ពស់ធៀបនឹងប្រទេសជាដៃគូប្រកួតប្រជែងសម្រាប់ការនាំចេញ iv/-វិស័យកសិកម្មងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និង v/-ដុល្លាររូបនីយកម្មនៅមានកម្រិតខ្ពស់។

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA